

# បទអន្តរាគមន៍
## របស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
## (ឧ.វ.ប.ន.)

# កម្មវិធីសន្និបាតបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០២៤
# និងលើកទិសដៅអនុវត្តឆ្នាំ២០២៥
# របស់ក្រសួងធនធានទឹក និងឧតុនិយម

ថ្ងៃព្រហស្បតិ៍ ១រោច ខែមាឃ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
ត្រូវនឹងថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២៥



ទឹកស្អាតសម្រាប់ទាំងអស់គ្នា

# មាតិកា

១. សមត្ថកិច្ចក្រសួងឧ.វ.ប.ន

២. គោលដៅ-គោលការណ៍នៃការផ្គត់ផ្គង់ទឹកស្អាត

៣- ការប្រើប្រាស់ប្រភពទឹក

៤- លទ្ធផលសង្ខេបនៃការផ្គត់ផ្គង់ទឹកស្អាត

៥- ស្ថិតិរោងចក្រ និង SME

៦- បញ្ហាប្រឈម

៧- កិច្ចការគួរយកចិត្តទុកដាក់បន្ត និងសំណើជាអនុសាសន៍

## ១. សមត្ថកិច្ចក្រសួងឧ.វ.ប.ន

- "ដឹកនាំនិងគ្រប់គ្រងវិស័យឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ រួមបញ្ចូលទាំងវិស័យសិប្បកម្ម និងទឹកស្អាត នៃព្រះរាជាណាចក្រកម្ពុជា" *(ច្បាប់ស្តីពីការបង្កើតក្រសួងឧ.វ.ប.ន.)*
  + សម្របសម្រួលសេដ្ឋកិច្ចក្រៅប្រព័ន្ធ។
- គ្រប់គ្រងការផ្តល់សេវាផ្គត់ផ្គង់ទឹកស្អាតដែលមានលក្ខណៈអាជីវកម្ម នៅទូទាំងព្រះរាជាណាចក្រកម្ពុជា *(មាត្រា២នៃច្បាប់ស្តីពីការគ្រប់គ្រងទឹកស្អាត)*។
- ការផ្តល់សេវាផ្គត់ផ្គង់ទឹកស្អាត ជាសមត្ថកិច្ចគ្រប់គ្រងនិងការទទួលខុសត្រូវដោយផ្ទាល់របស់រដ្ឋ។ រដ្ឋអាចផ្តល់សិទ្ធិជូនវិស័យឯកជន ដើម្បីផ្តល់សេវាផ្គត់ផ្គង់ទឹកស្អាតជូនប្រជាពលរដ្ឋនិងផ្នែកផលិតកម្ម សេវាកម្ម ដោយអនុលោមតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន *(មាត្រា៤នៃច្បាប់ស្តីពីការគ្រប់គ្រងទឹកស្អាត)* ។

- ការផ្តល់សេវាផ្គត់ផ្គង់ទឹកស្អាតគឺ សេវាសម្អាត (ប្រព្រឹត្តកម្ម) រក្សា និងបញ្ជូនចែកចាយដល់ទីតាំងអតិថិជន *(ថ្លៃទឹកស្អាត គឺជាថ្លៃសេវា ហើយខុសគ្នាអាស្រ័យភូមិសាស្ត្រនិងលក្ខខណ្ឌនៃប្រភពទឹក)*។ មូលហេតុថ្លៃទឹកខុសគ្នា (ប្រសាសន៍ **សម្តេចតេជោ** កាលពីថ្ងៃទី២ ខែមេសា ឆ្នាំ២០១៩ ក្នុងខេត្តកំពត)
- ជាការចាំបាច់, ក្រសួងឧ.រ.ប.ន. ត្រូវការការចូលរួមសហការជិតស្និទ្ធជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ដៃគូជាតិ អន្តរជាតិ រួមទាំងរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីអនុវត្តន៍បាននូវសមត្ថកិច្ចរបស់ខ្លួន ជាពិសេស ក្រសួងធនធានទឹក និងឧតុនិយម, ក្រសួងអភិវឌ្ឍន៍ជនបទ, ក្រសួងសាធារណការ និងដឹកជញ្ជូន, ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ.... ជាដើម

ដូចប្រសាសន៍ដ៏ខ្ពង់ខ្ពស់របស់ **សម្តេចតេជោ ហ៊ុន សែន** អតីតនាយករដ្ឋមន្ត្រី ដែលបានប្រកាសគាំទ្រឱ្យប្រើប្រាស់ពាក្យស្លោក *«ទឹកស្អាតសម្រាប់ទាំងអស់គ្នា»* កាលពីថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ២០២១



- **សម្ដេចតេជោ** បានថ្លែងសង្កត់ធ្ងន់ថា *«ការកំណត់ទិសដៅនេះ ធ្វើឱ្យយើងទាំងអស់គ្នាគិតគូរដោយហ្មត់ចត់បំផុត ទៅលើសកម្មភាពទាំងឡាយ ដើម្បីផ្ដល់ទឹកស្អាតសម្រាប់ទាំងអស់គ្នា»*
- *ដូច្នេះ* ទាំងអ្នកប្រើប្រាស់(គឺសាធារណជនទាំងអស់) ទាំងអ្នកផ្គត់ផ្គង់ មានផ្នត់គំនិតតែមួយដូចគ្នាគឺ ***ទឹកស្អាតជារបស់ទាំងអស់គ្នា, ជាសិទ្ធិមនុស្ស, ជាបញ្ហារួម***
- ការចូលរួមបំពេញកាតព្វកិច្ចរួមគ្នា ធ្វើយ៉ាងណាឱ្យប្រជាពលរដ្ឋទទួលបានទឹកស្អាតប្រើប្រាស់ទាំងអស់គ្នា ទាំងនៅទីក្រុង ទីប្រជុំជន ភូមិសាស្ត្រអាទិភាព និងជនបទ ដោយការសហការគាំទ្រគ្នាទៅវិញទៅមក សាមគ្គីគ្នាជាធ្លុងមួយ បង្កើតជាបរិយាកាសសុខដុមនីយកម្មនៅតាមមូលដ្ឋាន ស្របតាមអភិក្រម "**ឥរភាពនៃប្រព័ន្ធតួអង្គតែមួយ**"។

# ២. គោលដៅ-គោលការណ៍នៃការផ្គត់ផ្គង់ទឹកស្អាត

## គោលដៅ៖

ក្របខណ្ឌគោលដៅអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជាឆ្នាំ២០១៦-២០៣០ (CSDGs) បានកំណត់ថា *"ត្រឹមឆ្នាំ ២០៣០ សម្រេចនូវការទទួលបានសាកលកម្មនិងសមធម៌នូវទឹកបរិភោគដែលមានសុវត្ថិភាព និងថ្លៃសមរម្យ សម្រាប់ប្រជាជនទាំងអស់"*

(CAMBODIAN SUSTAINABLE DEVELOPMENT GOALS FRAMEWORK – CSDGs, 2016-2030)

## គោលការណ៍៖

- មានតម្លាភាព និងសមធម៌ ក្នុងការផ្តល់សេវាផ្គត់ផ្គង់ទឹកស្អាត
- មានសមភាព និងមិនមានការរើសអើង រវាងអ្នកផ្តល់សេវានិងអ្នកទទួលសេវាផ្គត់ផ្គង់ទឹកស្អាត
- លើកទឹកចិត្តដល់វិនិយោគិនជាតិនិងអន្តរជាតិឱ្យចូលរួមវិនិយោគក្នុងវិស័យទឹកស្អាត
- ផ្តល់សេវាផ្គត់ផ្គង់ទឹកស្អាតដោយឈរលើលក្ខខណ្ឌ៤យ៉ាងគឺ ទឹកស្អាតត្រូវមាន

  *គុណភាព សុវត្ថិភាព និរន្តរភាព និង ថ្លៃសមរម្យ*

## អត្ថន័យនៃលក្ខខណ្ឌទាំង៤យ៉ាង គុណភាព សុវត្ថិភាព និរន្តរភាព និង ថ្លៃសមរម្យ

- **គុណភាព (Quality)**៖ ត្រូវស្របតាមស្តង់ដាកម្ពុជាស្តីពីគុណភាពទឹកស្អាត គ្មានជាតិពុល មិនមានមេរោគ ដើម្បីធានាសុខភាពសាធារណៈ។
- **សុវត្ថិភាព (Water Safety Plan)**៖ ការវាយតម្លៃនិងបង្ការជាមុន ដើម្បីកាត់បន្ថយហានិភ័យដែលអាចមានចំពោះគុណភាពទឹក និងនិរន្តរភាព រួមទាំងភាពធន់នឹងអាកាសធាតុ។
- **និរន្តរភាព (Sustainability)**៖
  - **ចីរភាព (Sustainability)** គឺមានមិនដាច់ និងគ្រប់គ្រាន់ គ្រប់ពេល
  - **និរន្តរភាព (Continuity)** គឺមានជាដរាប យូរអង្វែង រៀងរហូត
- **ថ្លៃសមរម្យ (Affordable Tariff)**៖ ថ្លៃឬតារាងថ្លៃដែលអាចទទួលយកបាន (លទ្ធភាពទិញនិងទូទាត់តាមបរិមាណតម្រូវការជាមូលដ្ឋាន) សម្រាប់គ្រប់ប្រភេទអតិថិជន ជាពិសេសអតិថិជនដែលមានលទ្ធភាពទាប។

# ខ្លឹមសារនៃសមតាព និងសមធម៌

**សមភាព** (EQUALITY) **និង សមធម៌** (EQUITY)



# ខ្លឹមសារនៃសមតាព សមធម៌ និងបរិយាបន្ន

**សមភាព** (EQUALITY) **និង សមធម៌** (EQUITY)



## ៣- ការប្រើប្រាស់ប្រភពទឹក

(មាត្រា២៥នៃច្បាប់ស្តីពីការគ្រប់គ្រងទឹកស្អាត)

- "ប្រតិបត្តិករ អាចប្រើប្រាស់ប្រភពទឹកទៅតាមលក្ខណៈភូមិសាស្ត្រដែលអំណោយផលនិងតាមមធ្យោបាយដែលខ្លួនមាន សម្រាប់ធ្វើប្រព្រឹត្តកម្ម។ ការប្រើប្រាស់ប្រភពទឹកនេះ ត្រូវគោរពនិងធ្វើកិច្ចសហការ ជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិ និង/ឬ ក្រសួង ស្ថាប័នពាក់ព័ន្ធក្នុងការគ្រប់គ្រង ថែរក្សា និងការពារប្រភពទឹក ដោយអនុលោមតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន។

ក្រសួងទទួលបន្ទុកវិស័យទឹកស្អាត ក្រសួងទទួលបន្ទុកវិស័យធនធានទឹក ក្រសួង ស្ថាប័នពាក់ព័ន្ធនិងរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវសហការគ្នាក្នុងការចាត់វិធានការ ថែរក្សា ការពារប្រភពទឹកសម្រាប់បម្រើឱ្យការផ្គត់ផ្គង់ទឹកស្អាត។"

*ជាការពិត* ក្រសួងធនធានទឹក និងឧតុនិយម តាំងពីដើមរៀងមក តែងបានបង្ករលក្ខណៈងាយស្រួលដល់ក្រសួងឧ.វ.ប.ន. ក្នុងការអនុញ្ញាតឱ្យប្រតិបត្តិករទឹកស្អាតទាំងរដ្ឋ និងឯកជន ដកយកប្រភពទឹក ការប្រើប្រាស់ទឹកឆៅពីទន្លេ ស្ទឹង បឹង ទំនប់ ប្រឡាយ... ដើម្បីធ្វើប្រព្រឹត្តកម្មនិងផ្គត់ផ្គង់ទឹកស្អាត។ ការណ៍នេះ បានផ្តល់លទ្ធភាពឱ្យវិស័យផ្គត់ផ្គង់ទឹកស្អាត អាចឆ្លើយតបបានទៅនឹងតម្រូវការរបស់ក្នុងជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ និងការអភិវឌ្ឍសេដ្ឋកិច្ច សង្គមក្នុងមូលដ្ឋាន *(ផលិតកម្ម, សេវាកម្ម, បង្កើតមុខរបរ, ការលើកកម្ពស់សុខភាពសាធារណៈ និងសុខមាលភាពសង្គម....)*

☞ *ជាឧទាហរណ៍*៖

*ក្នុងបរិមាណទឹកស្អាតដែលផ្គត់ផ្គង់ជាក់ស្តែងក្នុងឆ្នាំ២០២៤កន្លងទៅប្រមាណ ៥៣០ លាន ម៣ ហើយតម្រូវការនេះនឹងកើនដល់ប្រមាណ ១,៣ ពាន់លាន ម៣ នៅឆ្នាំ២០៣០*

មានឧទាហរណ៍ជាក់ស្តែងថែមទៀត អំពីការជួយអន្តរាគមន៍របស់ក្រសួងធនធានទឹក និងឧតុនិយម ក្នុងការដោះស្រាយបញ្ហាប្រភពទឹកសម្រាប់វិស័យទឹកស្អាត ដូចជា នៅទីរួមខេត្តមណ្ឌលគិរី, នៅក្រុងសិរីសោភ័ណ, នៅស្រុកស្ទោង ខេត្តកំពង់ធំ, នៅតំបន់រណបតាមប្រឡាយទឹករលាំងជ្រៃចុះពីខេត្តកំពង់ស្ពឺ មកដល់ខេត្តកណ្តាល, ស្ទឹងសង្កែ ខេត្តបាត់ដំបង, ទំនប់ត្រពាំងថ្មខេត្តបន្ទាយមានជ័យ, ទន្លេវៃគោ ខេត្តស្វាយរៀង....... ជាដើម។ល។

# ៤- លទ្ធផលសង្ខេបនៃការផ្គត់ផ្គង់ទឹកស្អាត




សមាមាត្របរិមាណទឹកផលិតសរុប
(រដ្ឋាករទឹក និងប្រតិបត្តិករឯកជន)






**សមាមាត្រភូមិក្នុងប្រកាសអនុញ្ញាតសរុប**
**(រដ្ឋាករទឹក និងប្រតិបត្តិករឯកជន)**




**សមាមាត្រភូមិមានបណ្ដាញទឹកស្អាតសរុប**
**(រដ្ឋាករទឹក និងប្រតិបត្តិករឯកជន)**






សមាមាត្រគ្រួសារក្នុងតំបន់សេវាកម្មសរុប
(រដ្ឋាករទឹក និងប្រតិបត្តិករឯកជន)




សមាមាត្រតំណសរុប
(រដ្ឋាករទឹក និងប្រតិបត្តិករឯកជន)



## អត្រាគ្រួសារទទួលបានទឹកស្អាតទូទាំងប្រទេស




ខែមករា ឆ្នាំ២០២៥

## អត្រាភូមិមានបណ្ដាញទឹកស្អាតទូទាំងប្រទេស




ខែមករា ឆ្នាំ២០២៥

## ៥- ស្ថិតិរោងចក្រ SME និងកម្លាំងពលកម្ម (ក្រសួងឧ.វ.ប.ន.)

- ចំនួនរោងចក្រធុនធំសរុប៖ ២ ៤២៥ រោងចក្រ ក្នុងនោះ
  - តំបន់សេដ្ឋកិច្ចពិសេសចំនួន ៣០ មាន ៥៥៣ រោងចក្រ
  - សួនឧស្សាហកម្មចំនួន ២០ មាន ២០ មាន ១១៣ រោងចក្រ
- ពលកម្មសរុប៖ ១ ១៦០ ១៨១ នាក់ (៧៣,៥% ជាស្ត្រី)
- តម្រូវការទឹកសរុបប្រមាណ៖ ២៥ លានម៣/ឆ្នាំ
- ចំនួនសហគ្រាសធុនតូចនិងមធ្យម និងសិប្បកម្ម សរុបចំនួន៖ ៤៣ ៩៧០
- ពលកម្មសរុប៖ ៤៧៦ ២២៣ នាក់ (ស្ត្រី ៣០%)

## ៦- បញ្ហាប្រឈម

- តំបន់ដែលនៅទំនេរមួយចំនួនមិនមានសក្តានុពល ( *អន្តរាគមន៍៖ ប្រភពទឹក, ឧបត្ថម្ភធន និងទឹកស្អាតជនបទ*)
- កត្តាធម្មជាតិ៖ ការបម្រែបម្រួលអាកាសធាតុ និងគ្រោះធម្មជាតិ
- កត្តាមនុស្ស៖ គម្រោងអភិវឌ្ឍន៍ និងសកម្មភាពនានា ធ្វើឱ្យប៉ះពាល់
  - *បណ្តាញទឹកស្អាត៖ គុណភាពទឹក សេដ្ឋកិច្ច និងនិរន្តរភាពសេវា*
  - *ប្រភពទឹក៖ បរិមាណ និងគុណភាព*
- មិនមានព័ត៌មាន( ជាមុន )អំពីគម្រោងអភិវឌ្ឍន៍ដែលមានតម្រូវការទឹកស្អាត
- ស្ថានភាពប្រតិបត្តិករឯកជនមួយចំនួន នៅមិនទាន់ឆ្លើយតបលក្ខខណ្ឌតម្រូវ
- ធនធានមនុស្សក្នុងវិស័យនៅមានកម្រិត
- យន្តការសម្របសម្រួលការងារជាអន្តរស្ថាប័ននៅជួបលំបាកដោយអន្លើ ជាពិសេស នៅក្នុងពេលដោះស្រាយផលប៉ះពាល់ដល់បណ្តាញទឹកស្អាត ឬបញ្ហាគ្រោះធម្មជាតិ ឬបញ្ហាដែលកើតឡើងក្នុងករណីបន្ទាន់
- ការយល់ដឹងរបស់ប្រជាពលរដ្ឋ និងភាគីពាក់ព័ន្ធអំពីវិស័យទឹកស្អាតនៅមានកម្រិត។

*កម្រងរូបភាពខ្លះនៃបញ្ហាប្រឈមក្នុងស្លាយចុងក្រោយ*

## ៧- កិច្ចការគួរយកចិត្តទុកដាក់បន្ត និងសំណើជាអនុសាសន៍

- ចំពោះមុខ ដើម្បីធានានិរន្តរភាពនៃការផ្គត់ផ្គង់ទឹកស្អាត ស្នើសុំការបន្តកិច្ចសហការ និងការគាំទ្រយ៉ាងមុតមាំពីក្រសួងធនធានទឹក និងឧតុនិយម ក្នុងការសម្រួលដោះស្រាយបញ្ហាប្រភពទឹកដែលត្រូវជកប្រើប្រាស់សម្រាប់វិស័យទឹកស្អាត ដោយ៖

  ១) ស្នើសុំផ្តល់អាទិភាពសម្រាប់ទឹកស្អាត

  ២) ស្នើសុំក្រសួងធនធានទឹក និងឧតុនិយម បន្តជួយដោះស្រាយបញ្ហា ការផ្តល់ព័ត៌មានចាំបាច់ និងវិធានការអន្តរាគមន៍ ដើម្បីក្រសួងឧ.វ.ប.ន. មានលទ្ធភាពធ្វើការសម្របសម្រួល និងមានវិធានការដោះស្រាយបានទាន់ពេលជាមួយប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាត *(កន្លងទៅ តាមរយៈកិច្ចសហការរវាងក្រសួងទាំង២ បានផ្តល់ឱកាស និងលទ្ធភាពដល់និរន្តរភាពនៃការផ្គត់ផ្គង់ទឹកស្អាត និងនាំមកនូវស្ថិរភាពជីវភាព សេដ្ឋកិច្ច សង្គមបានល្អប្រសើរ។*

- ទឹកជាសម្បត្តិរួម, ជាបញ្ហារួម ចាំបាច់ត្រូវពង្រឹងអភិក្រម “ជវភាពនៃប្រព័ន្ធតួអង្គតែមួយ” ដើម្បីគោលដៅរួម
- បង្កើតយន្តការអន្តរក្រសួងស្ថាប័ន (ជាពិសេសថ្នាក់ក្រោមជាតិ) ដើម្បីសម្របសម្រួល និងដោះស្រាយការងារនិងបញ្ហាប្រភពទឹក
- បង្កើតយន្តការ និងពង្រឹងការគ្រប់គ្រង ថែរក្សា និងការពារប្រភពទឹក សំដៅធានាសន្តិសុខទឹក
- ការចែករំលែកព័ត៌មាន ទិន្នន័យ ផែនការ គម្រោងអភិវឌ្ឍន៍ និងបទដ្ឋានគតិយុត្តពាក់ព័ន្ធនានា។

# កម្រងរូបភាពខ្លះនៃបញ្ហាប្រឈម

# បញ្ហាប្រភពទឹក

## សំណល់ពីឧស្សាហកម្ម ខែឧសភា ឆ្នាំ២០២៣ ( ស្ទឹងព្រែកត្នោត )



ប្រ ភព៖ ភ្នំ ពេ ញ ប៉ុ ស្តិ៍





ប្រភព៖ FACEBOOK

# បញ្ហាប្រភពទឹក

## សកម្មភាពរកត្រីក្នុងបឹង ខែមេសា ឆ្នាំ២០២៤ (ខេត្តតាកែវ)







ប្រភព៖ FACEBOOK

# គ្រោះទឹកជំនន់

## ស្រុកមង្គលបូរី ខេត្តបន្ទាយមានជ័យ ខែតុលា ឆ្នាំ២០២០





# រាំងស្ងួត និងខ្សត់ទឹក (បូមទឹកតាមលទ្ធភាពរៀងៗខ្លួន ប៉ះពាល់ដល់ការប្រើប្រាស់ជាសាធារណៈ





# ការប៉ះពាល់បណ្តាញទឹកស្អាត







# ការប៉ះពាល់បណ្តាញទឹកស្អាត
# (នៅកន្លែងមួយចំនួន  កង្វះការគិតទុកជាមុន កង្វះអ្នកចេញមុខដោះស្រាយ  ធ្វើឱ្យដាច់ទឹករយៈពេលយូរ និងចំណាយធំ







# ការប៉ះពាល់បណ្តាញទឹកស្អាត (ដាច់ទឹក និងប្រើពេលយូរ ប្រជាពលរដ្ឋត្អូញត្អែរលំបាកថាពិបាកជាងការដាច់ភ្លើង)





# យើងធ្វើការរួមគ្នា ដើម្បីជាតិនិងប្រជាជន









សូ មអរ
គុ ណ